**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាជួបសម្ដេចប៉ាបនីប្រទេសមីយ៉ាន់ម៉ា**
**ថ្ងៃទី៣០ វិច្ឆិកា ២០១៧**

# *ព្រះនាងម៉ារីជួយឲ្យយើងមានកម្លាំង*

អត្ថបទទី១៖ រម ១០,៩-១៨
ដំណឹងល្អ៖ មថ ៤,១៨-២២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងទៅដល់កន្លែងព្រះនាងម៉ារីនៃហ្វាទីម៉ា នៅបារាំងយើងមានព្រះនាងម៉ារីនៅទីក្រុងលួដ៍ នៅកម្ពុជាយើងមានព្រះនាងម៉ារីនៃទន្លេមេគង្គ នៅប្រទេសម៉ិចស៊ិកូយើងមានព្រះនាងម៉ារីនៃវាត់តេម៉ាលេ នៅប្រទេសយូហ្គោស្លាវីយើងមានព្រះនាងម៉ារីនៃមិចហ្គុហេរ្យ នៅប្រទេសជប៉ុនយើងមានព្រះនាងម៉ារីនៃអាគីតា នៅប្រទេសវៀតណាមមានព្រះនាងម៉ារីននៅឡាវ៉ាង។ ក្រោយមកយើងឆ្ងល់ **មូលហេតុអ្វីមានព្រះនាងម៉ារីច្រើនម្ល៉េះ?** យើងស្គាល់ព្រះនាងម៉ារីម្ដាយព្រះយេស៊ូ នៅកន្លែងផ្សេងៗគ្នា។ ម្យ៉ាងនៅក្នុងគម្ពីរដំណឹងល្អយើងបានឮសម្លេងព្រះនាងម៉ារីតិចណាស់ ថ្ងៃនេះព្រះនាងម៉ារីនិយាយថា «**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**» និងនៅមង្គលការភូមិកាណាព្រះនាងម៉ារីនិយាយតែមួយមាត់ «**សូមធ្វើតាមអ្វីដែលលោកប្រាប់**» តែប៉ុណ្ណឹង។

ប៉ុន្តែសព្វថ្ងៃព្រះនាងម៉ារី បង្ហាញខ្លួននៅច្រើនកន្លែង ហើយនេះជាឱកាសមួយឲ្យយើងទទួលតាមរយៈព្រះនាងម៉ារីនូវការអប់រំ។ ថ្ងៃនេះ យើងគោរពព្រះនាងម៉ារីនៅទីក្រុងលួដ៍ ជាទីក្រុងមួយនៅប្រទេសបារាំង។ នៅឆ្នាំ១៨៦០ ព្រះនាងម៉ារីបានបង្ហាញខ្លួន ឲ្យយុវនារីម្នាក់ឈ្មោះប៉ែណាដេត ជាមនុស្សម្នាក់ដែលអត់បានរៀនសូត្រ។ ព្រះនាងម៉ារីបានបង្ហាញខ្លួនបីដង ដោយមានប្រសាសន៍ថា "**សូមទៅប្រាប់គេថា ខ្ញុំជានាងដែលគ្មានជំពាក់បាប**"។ ក្រោយមក គាត់ទៅប្រាប់លោកបូជាចារ្យដែលទទួលខុសត្រូវ នៅក្នុងព្រះសហគមន៍គាត់ ហើយលោកឪពុកនេះអត់ជឿគាត់ទេ គាត់អត់ទុកចិត្ត។ ក្រោយមកគាត់និយាយទៀត «**ខ្ញុំឃើញស្ត្រីម្នាក់ដែលពាក់អាវស និងផ្ទៃមេឃដែលភ្លឺយ៉ាងស្អាតមែនទែន គាត់ប្រាប់ថា សូមប្រាប់គេ ខ្ញុំជានាងដែលគ្មានជំពាក់បាប**»។ ហើយក្រោយមកគេឆ្ងល់ គេថាប្រហែលគាត់និយាយពិត ដោយសារគាត់អត់ចេះអាន អត់ចេះសរសេរ និងគាត់ប្រើពាក្យដែលគាត់អត់ដែលស្គាល់សោះ ដូច្នេះគាត់និយាយតាមព្រះនាងម៉ារី។ ក្រោយមក ព្រះនាងម៉ារីបង្ហាញ

នៅកន្លែងមួយដែលថា បន្តិចមានទឹកដែលចេញពីដី ហើយយកទឹកនេះទៅលាងភ្នែកមនុស្សខ្វាក់ម្នាក់អាចមើលឃើញ ពិតមែនគាត់មើលឃើញ។ ដូច្នេះពីពេលនោះតទៅ នៅទីក្រុងលួដ៍ គេបានរៀបចំរូងដែលមានព្រះនាងម៉ារី និងនៅក្បែរនោះមានទឹកហូរ និងមានអ្នកជំងឺទៅរាល់ឆ្នាំរាប់ពាន់នាក់ មានទាំងអ្នកពិការ អ្នកឈឺផ្សេងៗច្រើនណាស់។

ពីឆ្នាំ១៩៦០រហូតដល់ពេលនេះ ព្រះសហគមន៍បានទទួលស្គាល់ការអស្ចារ្យនៃការព្យាបាលអត់មានមូលហេតុប្រហែល១០០នាក់ នេះជាការអស្ចារ្យរបស់ព្រះជាម្ចាស់។ សព្វថ្ងៃនៅក្នុងពិភពលោកទាំងមូល ពេលយើងឃើញរូងមួយដែលមានព្រះនាងម៉ារីយើងដឹងថាជាព្រះនាងម៉ារីនៅទីក្រុងលួដ៍ ជាព្រះនាងម៉ារីដែលបានបង្ហាញខ្លួនដើម្បីដឹងថាព្រះនាងម៉ារីដែលគ្មានជំពាក់បាប។ ណែនាំឲ្យយើងទៅជាអ្នកបរិសុទ្ធ ធ្វើតាមព្រះនាងម៉ារីជានិច្ច និងព្រះនាងម៉ារីជួយយើង ដើម្បីមានកម្លាំងកាយកម្លាំងចិត្ត។

ដូច្នេះថ្ងៃនេះ សម្រាប់យើងដែលកំពុងធ្វើបូជនីយេសក៍ ជាឱកាសមួយដើម្បីនឹកឃើញ ដូចសិស្សសន្តយ៉ូស្វីនទៅពីណាំង(ម៉ាឡេស៊ី)ប៉ុន្មានខែមុន ជាកន្លែងដែលម្តាយរបស់ព្រះនាងម៉ារីបង្ហាញខ្លួន។ រាល់ឆ្នាំ១០ម៉ឺននាក់បានជួបជុំគ្នា នៅក្នុងបុណ្យព្រះនាងម៉ារីនៅទីក្រុងលួដ៍ថ្ងៃទី១១ និងថ្ងៃទី១៨ ខែកុម្ភៈ។ រាល់ឆ្នាំ មានទាំងពុទ្ធបរិស័ទ គ្រីស្តបរិស័ទ និងអ៊ីស្លាម ដើម្បីទទួលកម្លាំងមួយនៅក្នុងជីវិត។ ដូច្នេះសម្រាប់យើងដែលមកថ្ងៃនេះ យើងទទួលកម្លាំងមួយគឺអំណរសប្បាយ កុំឲ្យយើងធ្វើមុខអស់កម្លាំង ដោយសារព្រះនាងម៉ារីអត់អស់កម្លាំងទេ។ ព្រះនាងម៉ារី បានធ្វើដំណើរប្រញាប់ប្រញាល់ទៅសួរសុខទុក្ខយាយអេលីសាបេត។ ពីភូមិណាសារ៉ែតរហូតដល់អែការីម ដែលយាយអេលីសាបេតនៅគឺត្រូវចំណាយពេល៨ថ្ងៃដើម្បីធ្វើដំណើរ។ បើយើងនឹកឃើញព្រះនាងម៉ារីជិតដល់ថ្ងៃឆ្លងទន្លេ ធ្វើដំណើរពីណាសារ៉ែតទៅបេថ្លេហឹម គាត់ធ្វើដំណើរជាមួយលោកយ៉ូសែប និងគាត់ធ្វើដំណើរដោយអំណរសប្បាយ។ នៅពេលព្រះនាងម៉ារី ទៅដល់កន្លែងយាយអេលីសាបេត គាត់ច្រៀងកោតសរសើរព្រះជាម្ចាស់ ដោយសារចង់បង្ហាញអំណរសប្បាយដែលគាត់មាន។ ដូចគ្នានៅ ពេលព្រះនាងម៉ារីឆ្លងទន្លេ ប៉ុន្តែមិនមែននៅកន្លែងស្អាតទេ នៅក្រោលគោដែលមានសុទ្ធតែអាចម៍គោស្អុយណាស់ តែព្រះនាងម៉ារីសប្បាយចិត្ត ដោយសារបានកូន គឺព្រះយេស៊ូ។

ដូច្នេះសម្រាប់យើងចាំនេះៈ

**ទី១ ឲ្យយើងមានអំណរសប្បាយជានិច្ច** ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យទៅជាបុត្រធីតារបស់ព្រះអង្គ។ នៅប៉ុន្មានថ្ងៃនេះ ជាឱកាសមួយ ដើម្បីបង្ហាញអំណរសប្បាយរបស់យើង ដោយយល់ថាយើងជាព្រះសហគមន៍កាតូលិកកម្ពុជា ចូលរួមនៅក្នុងពិធីបុណ្យរួមជាមួយសម្តេចប៉ាប ដើម្បីសុំព្រះជាម្ចាស់ព្រះទានពរឲ្យយើងផ្ទាល់ និងក្រុមគ្រួសារយើងទៀត និងប្រទេសកម្ពុជាយើងទាំងមូល។

**ទី២ ឲ្យយើងតស៊ូជានិច្ច** ដោយសារជីវិតរបស់ព្រះនាងម៉ារីគឺការតស៊ូ នៅពេលសួរសុខទុក្ខយាយអេលីសាបេត នៅពេលឆ្លងទន្លេហើយចាំ៨ថ្ងៃធ្វើដំណើរទៅប្រទេសអេហ្ស៊ីបដោយសារស្តេចហេរ៉ូដសម្លាប់កូនង៉ែតទាំងអស់ ដូច្នេះ គាត់ធ្វើជាជនភៀសខ្លួននៅពេលនោះ។ ក្រោយមកគាត់តស៊ូនៅពេលស្តាប់ព្រះយេស៊ូមានបន្ទូលថា **អ្នកណាជាម្តាយខ្ញុំ?** យើងគិតប្រសិនបើយើងនិយាយពាក្យនេះ នៅមុខម្តាយយើងបើសិនយើងជាកូនកត្តញូនៅពេលមានម្តាយនៅជិត ហើយយើងឆ្លើយនៅទល់មុខម្តាយថា **អ្នកណាជាម្តាយខ្ញុំ?** ម្តាយប្រហែលឈឺចិត្តណាស់។ ចុងក្រោយបំផុត ព្រះនាងម៉ារីនៅក្បែរឈើឆ្កាង ដោយសារនៅសល់តែពីរនាក់ នៅពេលព្រះយេស៊ូកំពុងសោយទិវង្គត គ្រីស្តទូត មហាជន អ្នកជំងឺដែលព្យាបាលហើយ លោកសាខេ ស្ត្រីសាម៉ារី គេទៅអស់ហើយ អត់មានសល់នរណាទេ គេគេចខ្លួនអស់ហើយ។ ប៉ុន្តែនៅសល់ព្រះនាងម៉ារី និងលោកយ៉ូហាន ដែលកំពុងសំលឹងមើលព្រះយេស៊ូដែលកំពុងស្លាប់។ ហើយព្រះនាងម៉ារីឈឺចិត្តណាស់ ដោយសារទឹកចិត្តម្តាយដែលកំពុងឃើញកូនកំពុងស្លាប់ គាត់ឈឺដល់កម្រិតណាយើងគិតមិនដល់ទេ។ ប៉ុន្តែយើងយល់ថាព្រះនាងម៉ារី បានតស៊ូអស់មួយជីវិតរបស់គាត់ ដើម្បីបំពេញតួនាទី បេសកកម្មការត្រាស់ហៅដែលគាត់បានទទួល គឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់។

សម្រាប់ការអប់រំរបស់យើង គឺឲ្យយើងមានអំណរសប្បាយជានិច្ច ឲ្យយើងតស៊ូជានិច្ច ដើម្បីធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ដោយគាប់នឹងព្រះហឫទ័យរបស់ព្រះអង្គ។ ដូច្នេះខ្ញុំសង្ឃឹមនៅពេលនេះ និងនៅក្នុងពេលវេលាដែលយើងធ្វើបូជនីយសក៍ ជាឱកាសមួយនិយាយម្តងហើយម្តងទៀត យើងជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ យើងពោរពេញដោយអំណរសប្បាយ ទោះបីយើងមានទុក្ខលំបាកក៏ដោយ។ យើងមានអំណរសប្បាយ

ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើង ធ្វើជាអ្នកបម្រើពិសេសនៅក្នុងសង្គម និងព្រះសហគមន៍របស់យើង។

ដូច្នេះ យើងនៅស្ងៀមស្ងាត់ ទូលអង្វរព្រះអង្គឲ្យព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើយើងដោយបរិបូរណ៍ ដើម្បីឲ្យយើងមានកម្លាំងចិត្តនៅក្នុងការបម្រើ ដោយចេះតស៊ូ ដើម្បីសម្តែងអំណរសប្បាយដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់ ដោយសារព្រះយេស៊ូមានព្រះបន្ទូលថា «**ខ្ញុំយាងមកដើម្បីប្រទានអំណរសប្បាយដ៏ពេញលក្ខណៈ**»។ អាម៉ែន៕